**ខ្លឹមសារសង្ខេប** **សាលដីកាលេខ(៤៣២ខ)** **សាលាឧទ្ធរណ៍បាត់ដំបូង (១៥ ខែកញ្ញា ឆ្នាំ២០២២)**

**ពាក្យគន្លឹះ៖** អង្គហេតុក្រោមការស៊ើបអង្កេត -ឋានានុក្រមនៃភស្តុតាង -ភស្តុតាង

**១.ប្រវត្តិនីតិវិធី**

**ក.** ក្នុងខែមីនា ឆ្នាំ២០២១ អ្នកបោកគក់ **សហ** បានប្រទះឃើញកញ្ចប់ថង់ខ្មៅ (៤៦ក្រាម ម៉ាទឹកកក ភាពសុទ្ធជាង៣០ក្រាម) ក្នុងខោអាវ (ទទួលពីប្រពន្ធ **ពឡ** ដែលជាជនសង្ស័យនាពេលនោះ) រាយការណ៍ទៅ ប៉ូលីស ក៏បាននាំទៅឆែកឆេរ និងឃាត់ខ្លួន **ពឡ** នៅផ្ទះ។ ក្នុងពេលឆែកឆេរនោះ បានប្រទះឃើញថ្នាំមួយ គ្រាប់នៅក្រៅបន្ទប់ក្នុងបរិវេណផ្ទះ។ **ពឡ** បានសារភាពថា គាត់ធ្លាប់ទិញមកប្រើប្រាស់ ក៏ប៉ុន្តែ ថ្នាំញៀន រឹបអូសនៅទីកន្លែងបោកគក់ មិនមែនរបស់គាត់ទេ។ អង្គហេតុនេះ ត្រូវបានចោទជាបទប្រើប្រាស់ និងជួញ ដូរតាមមាត្រា៤០ និង៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន។

**ខ.** សាលាដំបូងខេត្តបន្ទាយមានជ័យ តាមសាលក្រមលេខ២១(ក) ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ បាន ផ្តន្ទាទោស៥ឆ្នាំ (ជាប់ពន្ធនាគារ៤ឆ្នាំ) ព្យួរធម្មតា១ឆ្នាំ។ **ពឡ** មិនសប្បាយចិត្ត បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹង សាលក្រមទាំងមូល៕ សវនាការសាលាឧទ្ធរណ៍បាត់ដំបង ចេញសាលដីកាលេខ៤៣២ (ខ)ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០២២ សម្រេចឲ្យ **ពឡ** រួចផុតពីបទចោទប្រកាន់ទាំងពីរប្រភេទ។ អគ្គព្រះរាជអាជ្ញាអមសាលា ឧទ្ធរណ៍ បានប្តឹងសាទុក្ខ។ សវនាការកំពូលនឹងប្រព្រឹត្តទៅក្នុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣។

**២. សំអាងហេតុនិងសេចក្តីសម្រេច**

**យល់ឃើញថា..**

៦. *ពុំមានភស្តុតាងគ្រប់គ្រាន់លើសពីវិមតិសង្ស័យ...គ្មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការចោ ទប្រកាន់លើឈ្មោះ **ពឡ**។*

៧. *អង្គហេតុដកហូតម៉ាទឹកកកមួយថង់ទម្ងន់ ៤៦ក្រម...និងថ្នាំញៀនគ្រាប់ចំនួន០១គ្រាប់ ដែលអង្គ ហេតុនេះ ខុសពីអង្គហេតុដែលបានលើកឡើងដោយឈ្មោះ **សហ** និងមន្ត្រីនគរបាលយុត្តិធម៌។*

៨. *សាលាដំបូង...បានផ្អែកតែលើចម្លើយ **ពឡ** នៅមន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែចម្លើយនេះត្រូវបាន ជនជាប់ចោទបដិសេធតាំងពីដំណាក់កាលអយ្យការអម...មក...។*

១០. *ការសម្រេចផ្តន្ទាទោសលើ..**ពឡ** ពីបទប្រើប្រាស់ខុសច្បាប់នូវសារធាតុញៀន...ពុំមានលក្ខណៈ ត្រឹមត្រូវនោះទេ ព្រោះតាមបញ្ញត្តិនៃមាត្រា៤៥ កថាខណ្ឌ១នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន...ពុំ ឃើញមានភស្តុតាងជាឯកសារណាមួយដែលបញ្ជាក់ថា ជនជាប់ចោទឈ្មោះ **ពឡ** ធ្លាប់រងនូវវិធានការព្យា*

*បាលដោយបង្ខំទេ។ ដូច្នេះ ពុំមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើ...**ពឡ** ពីបទប្រើប្រាស់...។*

សម្រេចបដិសេធសាលក្រមលេខ និងបង្គាប់ឲ្យដោះលែង **ពឡ**...។

## ៣. យោបល់

**ក.** តាមមាត្រា៣២១នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកម្ពុជាទទួលយកដោយសេរីនូវភស្តុតាង។ ច្បាប់ក៏មិនចែងអំពីឋានានុក្រមនៃប្រភេទភស្តុតាងដែរ។ ភស្តុតាងសម្រាប់ចោទប្រកាន់ត្រូវមានច្រើនគាំទ្រគ្នារឹងមាំ។ ចម្លើយសារភាពរបស់ជនជាប់ចោទ ឬជនរងគ្រោះ ឬសហចុងចោទតែមួយមុខមិនគ្រប់គ្រាន់ទេសម្រាប់ដាក់ពិរុទ្ធភាព។ ទោះបីជាយ៉ាងនេះក្តី សំអាងហេតុរបស់សាលាឧទ្ធរណ៍ ទំនងជាផ្តល់នូវភាពជឿទុកចិត្តលើភស្តុតាងរបស់ព្រះរាជអាជ្ញា (ចម្លើយជនសង្ស័យនៅមុខព្រះរាជអាជ្ញា) និងរបស់ចៅក្រមស៊ើបសួរជាង ចម្លើយនៅមុខនគរបាលយុត្តិធម៌នៅពេលមានខ្លឹមសារផ្ទុយគ្នា។ សហចៅក្រមស៊ើបអង្កេតនៃ អវតក បានអះអាងស្រដៀងនេះអំពីភស្តុតាងទទួលដោយមន្ត្រីតុលាការ និងមន្ត្រីក្រៅតុលាការ ដែលភស្តុតាងដោយមន្ត្រីតុលាការ មានភាពទុកចិត្តជាង ដោយសារឆ្លងកាត់នីតិវិធីត្រឹមត្រូវ (ដីកាដំណោះស្រាយ អវតក សំណុំរឿង០០៤/២ កថាខ័ណ្ឌទី១០៨)។ **ខ.** សាលាឧទ្ធរណ៍អះអាង ឲ្យមានការញែកគ្នាឲ្យដាច់ចំពោះអង្គហេតុមុនអង្គហេតុដែលស៊ើបដោយនគរបាលយុត្តិធម៌។ ក្នុងន័យថា អង្គហេតុមុន (ការប្រើប្រាស់ឬជួញដូរ មុនថ្ងៃឃាត់ខ្លួន ត្រូវឆ្លងកាត់ការស៊ើបដោយឡែកមួយ មិនបានយកមកបូកបញ្ចូល លើសពីអ្វីមានចែងក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងបានធ្វើការស៊ើបអង្កេត)។ ស្រដៀងគ្នានេះ តុលាការកំពូល (សាលដីកាតុលាការកំពូលលេខ៣៣៣ឆ្នាំ២០២០ទំ. ៧) បានស្នើឲ្យតុលាការជាន់ទាបបែងចែកច្បាស់រវាងអង្គហេតុមុន និងអង្គហេតុក្រោមការស៊ើបអង្កេត។ ការដាក់បញ្ចូលគ្នា ជាមូលហេតុមួយ ដែលតុលាការកំពូលបញ្ជូនសំណុំរឿងឲ្យសាលាឧទ្ធរណ៍ពិនិត្យឡើងវិញ។ **គ.** ក្នុងរឿងនេះ សារធាតុញៀនរឹបអូសបានគឺពីខោអាវ នៅកន្លែងបោកគក់ (មានការអះអាងថាជាខោអាវ របស់ជនសង្ស័យ ដែលយកទៅបោកគក់)។ សាលាឧទ្ធរណ៍មានមន្ទិលជាច្រើនលើអង្គហេតុនេះ។ នេះចង់បង្ហាញថា វាមិនមែនជាភស្តុតាងផ្ទាល់ភ្ជាប់ទៅនឹងជនជាប់ចោទ នាំឲ្យមានការអះអាងថាបានប្រព្រឹត្តិល្មើស។ យ៉ាងតិច មានសាលដីកាតុលាការកំពូលមួយ បានអះអាងស្រដៀងគ្នានេះ អំពីភាពប្រយោលនៃភស្តុតាង (សាលដីកាតុលាការកំពូលលេខ៣៩៥ ឆ្នាំ២០២២ ទំ.៦)។

**<u>សូមអានឯកសារពាក់ព័ន្ធ</u>៖** ១. ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ២. ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យ ៣. ដីកាសន្និដ្ឋានស្ថាពរ ៤. ដីកាដំណោះស្រាយ ៥. សាលក្រមលេខ១១ និង សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។